**សុន្ទរកថារបស់ លោក ជីបា តាយហ្សូ**
**លេខាទី២ ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់គម្រោងកែលម្អផ្លូវ ក្នុងឃុំឆែបពីរ ស្រុកឆែប ខេត្តព្រះវិហារ**
ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧

- **សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ**
- **សូមគោរព ឯកឧត្តម អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ**
- **សូមគោរព លោក សំ លាងទ្រី ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំសប្បាយចិត្តណាស់ ដែលបានមកចូលរួមក្នុងពិធីសម្ពោធផ្លូវ ក្នុងឃុំឆែបពីរ ស្រុកឆែបពីរ ខេត្តព្រះវិហារ ជាមួយវត្តមានរបស់ **ឯកឧត្តម អ៊ុន ចាន់ដា** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ។

ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ គឺជាវិស័យអាទិភាពមួយនៃកិច្ចសហប្រតិបត្តិការរបស់ជប៉ុនសម្រាប់កម្ពុជា ហើយ ជាក់ស្តែងគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជាច្រើន ត្រូវបានអនុវត្តនៅតាមទីជនបទ។ ឥឡូវនេះ ខ្ញុំពិតជាសប្បាយ រីករាយណាស់ ដែលបានឃើញផ្លូវនេះធ្វើបានស្អាតល្អ ក្រោយជំនួយគូសាណូណិ។

ខ្ញុំទទួលស្គាល់ថា ការកែលម្អផ្លូវនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណជា ៣,២០០នាក់ដែលរស់នៅ ក្នុងតំបន់នេះ។ គម្រោងនេះ នឹងផ្តល់ភាពងាយស្រួលជាងមុនដល់ប្រជាជនក្នុងការធ្វើដំណើរពីភូមិមួយទៅភូមិមួយ និងទៅកាន់ផ្លូវជាតិ ជាពិសេសនៅរដូវវស្សា។

ខ្ញុំសង្ឃឹមថា មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ នឹងថែទាំផ្លូវ និងលូនេះឲ្យបានល្អ ដើម្បីអោយប្រជា ជនទាំងអស់ អាចទទួលបានអត្ថប្រយោជន៍យូរអង្វែង។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងការកោតសរសើរចំពោះលោក-អ្នកទាំងអស់ ដែលបានរួមចំណែកធ្វើឲ្យការអនុ វត្តគម្រោងនេះប្រព្រឹត្តទៅបានយ៉ាងរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាផ្លូវនេះ នឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងប្រទេស យើងទាំងពីរ និងជួយពង្រឹងជាបន្តនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា៕

**សូមអរគុណ!**